00761151

E155

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 11 / 01 / 2012
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

**អង្គជំនុំជម្រះសាលាដំបូង**

**ជូនចំពោះ:** **ភាគីទាំងអស់នៃសំណុំរឿង ០០២** កាលបរិច្ឆេទ: ថ្ងៃទី១៥ ខែ ធ្នូ ឆ្នាំ ២០១១

**ពី:** Susan LAMB **មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន:** **លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ:** **ក្រុមសាក្សី និងអ្នកជំនាញបន្ទាប់ដែលអង្គជំនុំជម្រះត្រូវស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១**

អង្គជំនុំជម្រះសូមជូនដំណឹងទៅភាគីថានៅពេលសវនាការបន្តធ្វើនៅថ្ងៃ អង្គារ ទី ១០ ខែ មករា ឆ្នាំ ២០១២ ខាងមុខ អង្គជំនុំជម្រះនឹងកោះហៅម្តងទៀតនូវដើមបណ្តឹងរដ្ឋប្បវេណីដែលពុំទាន់ផ្តល់សក្ខីម្មចប់សព្វគ្រប់កាលពីអំឡុងសវនាការពីថ្ងៃទី ៥-១៦ ខែ ធ្នូ ឆ្នាំ ២០១១ កន្លងមក (មានជាអាទិ៍ដូចជា ដើមបណ្តឹងរដ្ឋប្បវេណីដែលមានអត្តលេខ TCCP ១៨៥ និង ១២៣) ដើម្បីទុកលទ្ធភាពឲ្យមេធាវីការពារក្តីសួរសំណួរ។ បន្ទាប់មកទៀត អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សីដែលមានអត្តលេខTCW ៥៤២ (អង្គជំនុំជម្រះធ្លាប់បានគ្រោងស្តាប់សាក្សីរូបនេះនៅក្នុងអំឡុងសវនាការដំណាក់កាលដំបូង) ហើយអង្គជំនុំជម្រះនឹងពន្យារពេលនៃការស្តាប់សក្ខីកម្មសាក្សីដែលមានអត្តលេខ TCW ៥៦៤ និង ៥៨៣។ អង្គជំនុំជម្រះសាលាដំបូងក៏នឹងបញ្ចប់ការសួរសំណួរជនជាប់ចោទពាក់ព័ន្ធនឹងកថាខណ្ឌ១៨-៣២នៃដីកាដំណោះស្រាយ ប្រសិនបើការសួរសំណួរពុំចប់សព្វគ្រប់ក្នុងអំឡុងសវនាការនាពេលបច្ចុប្បន្ន។ ជាចុងក្រោយ ខ្លួននឹងស្តាប់សក្ខីកម្មសាក្សី ឬអ្នកជំនាញបន្ថែមមួយចំនួនតូចទៀត (ខាងក្រោម) ដើម្បីបិទបញ្ចប់សវនាការលើផ្នែកនេះ។

នៅពេលសវនាការដំណាក់កាលដំបូងត្រូវបានបញ្ចប់ អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការដំណាក់កាលបន្ទាប់ទៀតលើចំណុចអង្គហេតុដូចមានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ E124/7.2 (បញ្ជីកថាខណ្ឌ និងផ្នែកនានានៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១) ដែលមានជាអាទិ៍ដូចជា រចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទងការងារ (ដីកាដំណោះស្រាយ កថាខណ្ឌ ៣៣-១១២, *៨៦៩-៨៧២, ១០០១-១០០៤ និង ១១៣១-១១៣៤*)។ អង្គជំនុំជម្រះនឹងសួរសំណួរទៅជនជាប់ចោទលើចំណុចអង្គហេតុទាំងនេះ មុនពេលបន្តសំណួរទៅសាក្សីដែលមានរាយនាមខាងក្រោម។

ហេតុដូច្នេះ នៅពេលសវនាការចាប់ផ្តើមបន្តធ្វើនៅថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០១២ អង្គជំនុំជម្រះនឹងអាចបំពេញកិច្ចទៅតាមលំដាប់លំដោយដូចខាងក្រោម៖

*ប្រវត្តិសាវតារ*

ដើមបណ្តឹងរដ្ឋប្បវេណីដែលមានអត្តលេខ TCP 185 និង 123[1]

ជនជាប់ចោទ[2]

សាក្សីដែលមានអត្តលេខ TCW 542

[សាក្សីដែលមានអត្តលេខ TCW 797][3]

*រចនាសម្ព័ន្ធរដ្ឋបាល និងរចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទងការងារ*

*(ដីកាដំណោះស្រាយ កថាខណ្ឌ ៣៣-១១២, ៨៦៩-៨៧២, ១០០១-១០០៤ និង ១១៣១-១១៣៤ (ឯកសារ E124/7.2))*

ជនជាប់ចោទ

សាក្សីដែលមានអត្តលេខ TCW 480

សាក្សីដែលមានអត្តលេខ TCW 780

សាក្សីដែលមានអត្តលេខ TCW 695

សាក្សីដែលមានអត្តលេខ TCW 307

សាក្សីដែលមានអត្តលេខ TCW 679

សាក្សីដែលមានអត្តលេខ TCW 645

សាក្សីដែលមានអត្តលេខ TCW 398

ក្នុងករណីដែលជនជាប់ចោទណាម្នាក់ពុំមានលទ្ធភាពឆ្លើយសំណួរពេញមួយថ្ងៃសវនាការ អង្គជំនុំជម្រះនឹងបន្តសួរសំណួរជនជាប់ចោទផ្សេងទៀត ឬសាក្សី (តាមលំដាប់លំដោយខាងលើ)។ ហេតុដូច្នេះ សវនាការដំណាក់កាលបន្ទាប់អាចផ្តោតសំខាន់លើការសួរសំណួរជនជាប់ចោទ ហើយមានតែសាក្សីមួយចំនួនតូចប៉ុណ្ណោះដែលអាចអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្ម។

---

[1] ការបញ្ចប់ការសួរសំណួរបានធ្វើកាលពីអំឡុងសវនាការថ្ងៃទី ៥-១៦ ខែ ធ្នូ ឆ្នាំ ២០១១។

[2] ប្រសិនបើការសួរសំណួរជនជាប់ចោទលើចំណុចនេះពុំទាន់ចប់ត្រឹមថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១។

[3] លើកលែងតែអ្នកជំនាញដែលមានអត្តលេខ TCE 44 និង TCE 38 ពុំមានវត្តមានក្នុងអំឡុងសវនាការដំណាក់កាលបន្ទាប់ (ខាងក្រោម) ។ ប្រសិនបើមានអ្នកជំនាញណាម្នាក់ផ្តល់សក្ខីកម្ម, សាក្សីដែលមានអត្តលេខ TCW 797 នឹងត្រូវអង្គជំនុំជម្រះស្តាប់សក្ខីកម្មនៅសវនាការលើកក្រោយ។

00761153

E155

បន្ថែមពីលើសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណីដូចដែលបានបញ្ជាក់ខាងលើ អង្គជំនុំជម្រះសាលាដំបូងក៏នឹងព្យាយាមស្តាប់សក្ខីកម្មអ្នកជំនាញដែលមានអត្តលេខ TCE 44 និង TCE 38។ ដោយហេតុថាអង្គជំនុំជម្រះពុំទាន់មានលទ្ធភាពថាអ្នកជំនាញណាម្នាក់នឹងពិតជាមានវត្តមាននៅអំឡុងខែ មករា និង កុម្ភៈ ឆ្នាំ ២០១២ ខាងមុខ ភាគីនឹងទទួលបានការជូនដំណឹងអំពីកាលបរិច្ឆេទតាមការប៉ាន់ស្មាន នៃការស្តាប់សក្ខីកម្មអ្នកជំនាញទាំងនេះឆាប់ៗនៅពេលដែលអង្គជំនុំជម្រះទទួលបានព័ត៌មាន។ ប្រសិនបើពួកគេពុំអាចមានវត្តមានក្នុងអំឡុងសវនាការដំណាក់កាលបន្ទាប់ អង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មសាក្សីដែលមានអត្តលេខ TCW 797 ជំនួសវិញ។ ប៉ុន្តែបើពួកគេអាចមានវត្តមាននៅអំឡុងរយៈពេលខាងលើ ខ្លួននឹងស្តាប់សក្ខីកម្មរបស់សាក្សី TCW 797 នៅពេលក្រោយ។ អនុលោមតាមវិធាន៨០នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសូមប្រគល់ភារកិច្ចទទួលខុសត្រូវក្នុងការសួរសំណួរសាក្សី និងអ្នកជំនាញទាំងអស់ខាងលើទៅការិយាល័យសហព្រះរាជអាជ្ញា។

ថ្វីត្បិតលំដាប់លំដោយនៃការកោះហៅសាក្សី និងអ្នកជំនាញខាងលើមានចេតនាត្រូសត្រាយការត្រៀមរៀបចំរបស់ភាគីក៏ដោយ ក៏អង្គជំនុំជម្រះអាចកែប្រែលំដាប់លំដោយខាងលើតាមការចាំបាច់ដោយពុំចាំបាច់ជូនដំណឹងជាមុន។ ជាពិសេស លំដាប់លំដោយនេះអាចកែប្រែ ឬបន្ថែម បន្ទាប់ពីទទួលបានអនុសាសន៍របស់អង្គភាពគាំពារសាក្សី/អ្នកជំនាញ ពាក់ព័ន្ធនឹងវត្តមាន ឬសុខភាពរបស់បុគ្គលណាម្នាក់។ ហេតុដូច្នេះ អង្គជំនុំជម្រះសូមជូនដំណឹងទៅភាគីថាលំដាប់លំដោយនៃការកោះហៅសាក្សី និងអ្នកជំនាញអាចមានការកែប្រែ។

អង្គជំនុំជម្រះសាលាដំបូងក៏នឹងអនុញ្ញាតឱ្យភាគីដាក់ឯកសារ (ពាក់ព័ន្ធនឹងប្រវត្តិសាវតារ រចនាសម្ព័ន្ធ និងរចនាសម្ព័ន្ធនៃការប្រាស្រ័យទាក់ទងការងារ) ជូនអង្គជំនុំជម្រះ និងការជំទាស់នានាដែលត្រូវស្តាប់នៅសវនាការដំណាក់កាលបន្ទាប់ ដោយមានបញ្ជាក់កាលបរិច្ឆេទច្បាស់លាស់នៅពេលឆាប់ៗខាងមុខ។

អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ថាសវនាការដំណាក់កាលបន្ទាប់នឹងចាប់ផ្តើមពីថ្ងៃ អង្គារ ទី ១០ ខែ មករា ឆ្នាំ ២០១២ រហូតដល់ថ្ងៃ ព្រហស្បតិ៍ ទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២។ បន្ទាប់ពីឈប់សម្រាក អង្គជំនុំជម្រះនឹងបន្តធ្វើសវនាការនៅថ្ងៃ ច័ន្ទ ទី ១២ ខែ មីនា ឆ្នាំ ២០១២។